ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារជំនួយស្មារតី

## សម្រាប់

## ការពិនិត្យបញ្ជីឈ្មោះ

## និងការចុះឈ្មោះបោះឆ្នោត

## ឆ្នាំ២០២៦

# មាតិកា


**គោលបំណង** ......... ១

I. **ការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត** ......... ២

១. ការិយាល័យបោះឆ្នោត ......... ២

២. ការិយាល័យចុះឈ្មោះបោះឆ្នោត ......... ២

ក. ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ......... ២

ខ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់) ......... ២

គ. គំនូសតាងស្តីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ......... ៣

៣. ការបិទផ្សាយ និងការផ្សព្វផ្សាយបញ្ជី និងឯកសារនានាទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ......... ៣

ក. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ......... ៣

ខ. ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ......... ៣

គ. ការផ្សព្វផ្សាយអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ......... ៤

៤. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ......... ៤

II. **ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)** ......... ៤

១. សមាសភាព ក.ច.ប ......... ៤

២. តួនាទី និងភារកិច្ចរបស់ ក.ច.ប ......... ៥

III. **សម្ភារ បរិក្ខារ កុំព្យូទ័រ ឯកសារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត** ......... ៦

១. សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ......... ៦

២. របៀបថែរក្សាសម្ភារ បរិក្ខារកុំព្យូទ័រ ......... ៦

IV. **ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត** ......... ៧

១. លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ......... ៨

២. លក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោត ......... ៩

៣. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ......... ៩

ក. ឯកសារដែលអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញ ក.ច.ប ដើម្បីសុំចុះឈ្មោះបោះឆ្នោត ......... ៩

ខ. ឯកសារ និងសាក្សីសម្រាប់ការស្នើសុំ ឯ.អ ......... ៩

គ. ឯកសារ និងសាក្សីសម្រាប់ការស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ......... ១០

V. **ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត** ......... ១០

១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ......... ១០

២. ជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត ......... ១១

៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ ........ ១១
ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ........ ១២
ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួច ........ ១៣
គ.ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយនាឆ្នាំកន្លងទៅ នៅឃុំ សង្កាត់ផ្សេង ........ ១៦
ឃ.ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ១៧
ង. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ ឆ្នាំ ........ ១៨
ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ២០
៤. ការពិនិត្យ និងសម្រេចរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ........ ២០
VI. **តំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត** ........ ២១
VII. **ការប្រើប្រាស់ទម្រង់បែបបទ** ........ ២២
VIII. **ការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប** ........ ២៥
១. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យបោះឆ្នោតនីមួយៗ ........ ២៥
២. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ និងនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ២៦
ក. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ........ ២៦
ខ. ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ២៧
៣. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប ........ ២៧
ក. ការវេចខ្ចប់ស្បោង «ខ» ទី១ ........ ២៧
ខ. ការវេចខ្ចប់ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ ........ ២៩
៤. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប ........ ៣០
៥. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ........ ៣០

ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ឃប ........ ៣០
ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនទៅនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត........ ៣២
៦. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀតដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប...... ៣៤
IX. **ការមិនផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ជាសាធារណៈសម្រាប់គោលដៅនៃការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់** ........ ៣៤
១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ... ៣៤
២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ........ ៣៥
X. **ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត** ........ ៣៥
១. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ........ ៣៦
ក. ករណីពាក្យបណ្ដឹងតវ៉ា........ ៣៦
ខ. ករណីពាក្យបណ្ដឹងជំទាស់ ........ ៣៧
២. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ........ ៣៨
**ឧបសម្ព័ន្ធ**........ ៣៩
ឧបសម្ព័ន្ធ១........ ៤០
ឧបសម្ព័ន្ធ២........ ៤១
ឧបសម្ព័ន្ធ៣........ ៤២
ឧបសម្ព័ន្ធ៤........ ៤៣
ឧបសម្ព័ន្ធ៥........ ៤៤
ឧបសម្ព័ន្ធ៦........ ៤៥
ឧបសម្ព័ន្ធ៧........ ៤៩
ឧបសម្ព័ន្ធ៨........ ៥០
ឧបសម្ព័ន្ធ៩........ ៥២
ឧបសម្ព័ន្ធ១០........ ៥៤
ឧបសម្ព័ន្ធ១១........ ៥៥
ឧបសម្ព័ន្ធ១២........ ៥៦

# អក្សរកាត់

| | | |
|---|---|---|
| ១- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២- | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៣- | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៤- | ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ៥- | ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| ៦- | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៧- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៨- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ៩- | ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត | ច.វ.ច.ប |
| ១០- | បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះ បោះឆ្នោតប្រចាំឆ្នាំ | ប.ន.ព.ច |
| ១១- | អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ | អ.ខ |
| ១២- | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត | ឯ.អ |
| ១៣- | នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| ១៤- | នាយកដ្ឋាន | ន. |
| ១៥- | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ឯកសារជំនួយស្មារតីនេះ មានគោលបំណងពន្យល់អំពីនីតិវិធី បច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមកម្មវិធីកុំព្យូទ័រ ដើម្បីឱ្យមន្ត្រីបោះឆ្នោត ជាពិសេស ក.ច.ប និង កបឃ.ស ទាំងអស់សិក្សាស្វែងយល់ និងអនុវត្តការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយលទ្ធផលល្អ។

ឯកសារជំនួយស្មារតីស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ បានដកស្រង់ចេញពីចំណុចគន្លឹះសំខាន់ៗតាមលំដាប់លំដោយពីបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសៀវភៅណែនាំសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ដែលការងារនេះត្រូវចាប់ផ្តើមពីថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ខាងមុខនេះនៅតាមឃុំ សង្កាត់។

ឯកសារជំនួយស្មារតីនេះ ក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ នេះ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

## I. ការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ តាមឃុំ សង្កាត់មានរយៈពេល ៥៥ថ្ងៃ ដោយត្រូវចាប់ផ្ដើមពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ រួចបញ្ចប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦។

### ១. ការិយាល័យបោះឆ្នោត

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០នាក់។ ក្នុងករណីការិយាល័យបោះឆ្នោតណាមួយ មានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុង៖

ក) ការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬ

ខ) ការិយាល័យបោះឆ្នោតណាដែលនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ឬ

គ) ការិយាល័យបោះឆ្នោតដែលបង្កើតថ្មីក្នុងភូមិជាមួយ។

### ២. ការិយាល័យចុះឈ្មោះបោះឆ្នោត

#### ក. ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមាននៅ ២ទីតាំងគឺ៖

- **នៅសាលាឃុំ សង្កាត់៖** ជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បងដែលបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅថ្ងៃចាប់ផ្ដើម និងថ្ងៃបញ្ចប់ដោយប្រើរយៈពេលប្រមាណមួយភាគពីរនៃរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសរុប
- **នៅតាមទូមិមួយចំនួនក្នុងឃុំ សង្កាត់៖** ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយប្រើរយៈពេលមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួមដែលបានកំណត់ឡើយ។

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតមកពីគ្រប់ភូមិ ក្នុងព្រំប្រទល់ឃុំ សង្កាត់។

#### ខ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)




- **បរិវេណខាងក្នុង** មានកាំប្រវែងយ៉ាងតិច១៥ម៉ែត្រ។
- **បរិវេណខាងក្រៅ** មានកាំប្រវែង១០០ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្ដែង ឬមានទម្រង់ផ្សេងពីនេះ។

### គ. គំនូសតាងស្ដីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ អាចបែងចែកពេលវេលាទៅតាមគំនូសតាង ដូចខាងក្រោម៖

| រយៈពេល ១៥ ថ្ងៃ<br>នៅសាលាឃុំ សង្កាត់ | រយៈពេល ២៥ ថ្ងៃ<br>នៅតាមភូមិមួយចំនួន | រយៈពេល ១៥ ថ្ងៃ<br>នៅសាលាឃុំ សង្កាត់ |
|---|---|---|
| ថ្ងៃទី៧ ដល់ថ្ងៃទី២១<br>ខែតុលា ឆ្នាំ២០២៦ | ថ្ងៃទី២២ ខែតុលា ដល់ថ្ងៃទី១៥<br>ខែវិច្ឆិកា ឆ្នាំ២០២៦ | ថ្ងៃទី១៦ ដល់ថ្ងៃទី៣០<br>ខែវិច្ឆិកា ឆ្នាំ២០២៦ |

☛ **សម្គាល់**

- ក្នុងករណីចាំបាច់ ក.ច.ប អាចកែសម្រួលរយៈពេលចុះឈ្មោះបោះឆ្នោតតាមភូមិ ដោយត្រូវជូនដំណឹងដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោត
- ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ កបឃ.ស ត្រូវបិទការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ៤ (បួន) លើក ដើម្បីបើកកិច្ចប្រជុំជាមួយ ក.ច.ប ត្រួតពិនិត្យការអនុវត្តដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ កិច្ចប្រជុំត្រួតពិនិត្យនេះត្រូវប្រព្រឹត្តទៅនៅ**ថ្ងៃទី១២ ថ្ងៃទី២៩ ខែតុលា ថ្ងៃទី៩ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៦**។

## ៣. ការបិទផ្សាយ និងការផ្សព្វផ្សាយបញ្ជី និងឯកសារនានាទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ក. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

កបឃ.ស ត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដូចខាងក្រោម៖

- **ទីតាំងបិទផ្សាយ៖** ១) នៅសាលាឃុំ សង្កាត់ និង
  ២) នៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់
- **កាលបរិច្ឆេទបិទផ្សាយ៖** នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦។

### ខ. ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥

កបឃ.ស ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែល គ.ជ.ប ផ្តល់សុពលភាពចុងក្រោយ ដូចខាងក្រោម៖

- **ទីតាំងបិទផ្សាយ៖** ១) នៅសាលាឃុំ សង្កាត់ និង
  ២) នៅទីប្រជុំជនក្នុងឃុំ សង្កាត់
- **កាលបរិច្ឆេទបិទផ្សាយ៖** នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦។

**ចំណាំ៖**

- បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ចំនួន១ច្បាប់ ទុកសម្រាប់ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ប្រើប្រាស់នៅពេលពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

គ. ការផ្សព្វផ្សាយអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) និងប្រធាន ក.ច.ប ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេលយ៉ាងតិច ៣ថ្ងៃ មុនថ្ងៃចាប់ផ្តើមធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស ត្រូវចាត់ចែងតាមលទ្ធភាព និងការចាំបាច់ឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត
- សម្រួលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ៣នាក់
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាព ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ ជូនដំណើរជនមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ថែរក្សាសុវត្ថិភាព និងសន្តិសុខ ដើម្បីបង្ការការបាត់បង់សម្ភារ បរិក្ខារនានាបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ប្រសិនបើសម្ភារ បរិក្ខារទាំងនោះរក្សាទុកនៅសាលាឃុំ សង្កាត់)
- រាយការណ៍ជាបន្ទាន់ជូនប្រធាន ក.ច.ប ដើម្បីរាយការណ៍ជូន កបឃ.ស តាមរយៈសមាជិក កបឃ.ស ប្រចាំការ ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

## II. ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

១. សមាសភាព ក.ច.ប

ឃុំ សង្កាត់នីមួយៗ ត្រូវមាន ក.ច.ប មួយដែលមាន៖

- ប្រធាន ១ (មួយ) រូប (ជ្រើសរើសដោយ គ.ជ.ប)
- អនុប្រធាន ១ (មួយ) រូប (ជាស្មៀនឃុំ សង្កាត់សាមី)
- ការីកុំព្យូទ័រ ១ (មួយ) រូប (ជ្រើសរើសដោយ គ.ជ.ប)
- ឃុំ សង្កាត់ធំដែលមានចំនួនប្រជាពលរដ្ឋច្រើន គ.ជ.ប អាចបន្ថែមសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប ១ (មួយ) រូប និងការីកុំព្យូទ័រ ១ (មួយ) រូប។

## ២. តួនាទី និងភារកិច្ចរបស់ ក.ច.ប

ក.ច.ប មានតួនាទី និងភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- គោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ឃ.ស) ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត (ច.វ.ច.ប) បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត (ប.ន.ព.ច) និងមានជំហរឯករាជ្យ អព្យាក្រឹត និងមិនលម្អៀង
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យល់ដឹងច្បាស់ និងចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព
- បំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់
- អនុវត្តតាមសេចក្តីសម្រេចរបស់ កបឃ.ស ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឬក្រុមប្រឹក្សាធម្មនុញ្ញក្នុងការចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- សហការជាមួយ លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ដើម្បីអនុវត្តនីតិវិធីលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង និងសហការជាមួយ លធ.ខប និង កបឃ.ស ដើម្បីជូនដំណឹងដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឱ្យមកបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត
- រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានទទួលក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត
- ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយដែលបង្កការរំខាន ឬ/និងការរំលោភបំពានលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណ

របស់អ្នកសុំចុះឈ្មោះបោះឆ្នោត។ លើកលែងតែមានការអនុញ្ញាតដូចមានចែងក្នុង ប.ន.ព.ច។ ការរំខាន ឬ/និងការរំលោភបំពានមានជាអាទិ៍ដូចខាងក្រោម៖

- ការកត់ត្រា ឬការថតយកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតពីកុំព្យូទ័រ
- ការកត់ត្រា ឬការថតឯកសាររបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ការព្យាយាមតាមគ្រប់មធ្យោបាយផ្សេងទៀត ដើម្បីកត់ត្រា ឬថតឯកសារ ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

## III. សម្ភារ បរិក្ខារ កុំព្យូទ័រ ឯកសារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

សម្ភារ បរិក្ខារ កុំព្យូទ័រសំខាន់ៗ សម្រាប់បម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ តាមកម្មវិធីកុំព្យូទ័រ មានសរុប១២មុខ (ដូចមានរាយនាមក្នុងសៀវភៅណែនាំ)។

ទម្រង់បែបបទដែលមានគំរូស្រាប់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សរុបមាន ២០មុខ។

### ២.របៀបថែរក្សាសម្ភារ បរិក្ខារកុំព្យូទ័រ

ក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ក.ច.ប ត្រូវរៀបចំដាក់សម្ភារ បរិក្ខារកុំព្យូទ័រទាំងអស់ចូលក្នុងកេស ដើម្បីរក្សាទុកឱ្យបានត្រឹមត្រូវ តាមការណែនាំដូចខាងក្រោម៖

☛ សម្ភារ បរិក្ខារដែលងាយនឹងបាក់បែក ដូចជាកុំព្យូទ័រយួរដៃ ឧបទស្សន៍កុំព្យូទ័រទី២ កាមេរ៉ាថតរូបភាព ស្កេនន័រស្នាមម្រាមដៃ Portable scanner 1 ឈុត ត្រូវដាក់ចូលក្នុងកាតាប។



កុំព្យូទ័រយួរដៃ




ឧបទស្សន៍កុំព្យូទ័រទី២



កាមេរ៉ាថតរូបភាព



ស្កេនន័រស្នាមម្រាមដៃ



Portable scanner 1 ឈុត

- សម្ភារ បរិក្ខារតូចៗណាដែលងាយបាត់ ដូចជា USB Flash, Modem, Sim Card, SD Card, Mouse, ... ត្រូវដាក់ចូលក្នុងកាបូប ឬកាតាប។


USB Flash


Modem, Sim Card


SD Card


Mouse

- សម្ភារ បរិក្ខារណាដែលធ្ងន់ៗត្រូវដាក់នៅខាងក្រោម រីឯសម្ភារ បរិក្ខារណាដែលស្រាលៗត្រូវដាក់នៅពីលើ។
- ត្រូវរៀបចំទុកដាក់សម្ភារ បរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោតទាំងអស់ចូលទៅក្នុងកេសស័ង្កសី រួចចាក់សោ និងរក្សាទុកនៅកន្លែងណាដែលមានសីតុណ្ហភាពត្រជាក់ល្មម ស្ងួត និងមានសុវត្ថិភាព។
- ត្រូវផ្ទៀងផ្ទាត់ឱ្យប្រាកដថា សម្ភារ ឯកសារ និងបរិក្ខារទាំងអស់មានគ្រប់មុខមុនពេលចាកចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត។
- ត្រូវយកកុំព្យូទ័រយួរដៃ និង Power Bank ទៅសាកថ្មឱ្យបានពេញនៅពេលល្ងាចក្រោយចប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ដើម្បីឱ្យមានថាមពលអគ្គិសនីពេញសម្រាប់បន្តការចុះឈ្មោះបោះឆ្នោតនៅថ្ងៃស្អែកទៀត (សម្រាប់ឃុំ សង្កាត់ណាដែលពុំមានថាមពលអគ្គិសនីគ្រប់គ្រាន់)។

## IV. **ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត**

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ក.ច.ប នឹងជួបៈ

- **អ្នកមកសុំចុះឈ្មោះបោះឆ្នោតគឺជាៈ**
  - ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត
  - ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ ដែលមានអាយុ ១៨ឆ្នាំឡើងគិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
  - ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី។
- **អ្នកមកស្នើសុំកែតម្រូវទិន្នន័យជីវប្រវត្តិគឺជាៈ**
  - ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ រួចហើយ ប៉ុន្តែឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើតក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ

- ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ រួចហើយ ប៉ុន្តែស្នើសុំប្តូរការិយាល័យពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ សង្កាត់ដដែល ឬសុំប្តូរពី ការិយាល័យមួយទៅការិយាល័យមួយទៀតក្នុងភូមិតែមួយ
- ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលបានប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) អស់សុពលភាព ឬ/និង ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ក្នុងការសុំចុះឈ្មោះបោះឆ្នោតនាឆ្នាំកន្លងទៅ បានមកស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតតាម អ.ខ ប្រភេទថ្មីរបស់គាត់

- **អ្នកមកស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រគឺជា៖**

ប្រជាពលរដ្ឋខ្មែរដែលបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប ផ្តិតមេដៃ) ក្នុងបញ្ជីបោះឆ្នោត ពីមុនមក

- **ការលុបឈ្មោះអ្នកបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតគឺ៖**

ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលបានទទួលមរណភាព ហើយសមាជិកគ្រួសារមករាយការណ៍ផ្ទាល់ជូន គ.ជ.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បី គ.ជ.ប អនុវត្តនីតិវិធីបន្ត។

## ១. លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋខ្មែរត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

## ២. លក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវ៖

- បង្ហាញខ្លួន និងមាន អ.ខ ឬ ឯ.អ នៅចំពោះមុខ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលនៅសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួន
- មានសញ្ជាតិខ្មែរ និងមានអាយុ១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត
- មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

## ៣. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត គឺ អ.ខ ។

### ក. ឯកសារដែលអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញ ក.ច.ប ដើម្បីសុំចុះឈ្មោះបោះឆ្នោត

| ឯកសារ / ករណី |  (អ.ខ) |  (ឯ.អ) |  (សៀវភៅស្នាក់នៅ) |  (សៀវភៅគ្រួសារ) |  លិខិតបញ្ជាក់ទីលំនៅ |
|---|---|---|---|---|---|
| មាន អ.ខ និងអាសយដ្ឋានដូច អ.ខ | ✓ | | | | |
| ពុំមាន អ.ខ ឬបាត់ ឬខូច ។ល។ | | ✓(ខ) | | | |
| មាន អ.ខ តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីកន្លែងសុំចុះឈ្មោះបោះឆ្នោត | ✓ | | ✓ | | |
| | ✓ | | | ✓ | |
| | ✓ | | | | ✓(គ) |

### ខ. ឯកសារ និងសាក្សីសម្រាប់ការស្នើសុំ ឯ.អ

អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួន ដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលគាត់ត្រូវចុះឈ្មោះបោះឆ្នោត ដោយនាំមកជាមួយនូវ៖

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្តីចម្លងព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ
- រូបថតសាមីខ្លួន ទំហំ៣×៤ ចំនួន ២សន្លឹក
- សាក្សី ២រូប ដែលមាន៖
  + សិទ្ធិបោះឆ្នោត
  + លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ទៅជាមួយ។

**គ. ឯកសារ និងសាក្សីសម្រាប់ការស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់**

អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ដោយនាំមកជាមួយនូវ៖

- អ.ខ របស់សាមីខ្លួន
- លិខិតអនុញ្ញាតស្នាក់នៅបណ្តោះអាសន្ន (ក៩) ចេញដោយនាយប៉ុស្តិ៍នគរបាលរដ្ឋបាលនៃឃុំ សង្កាត់របស់សាមីខ្លួន និង
- សាក្សី ១រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ។

## V. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ មានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាព។




**ចំណាំ៖** រាល់ការស្នើសុំត្រូវមានឯកសារសំអាងផ្លូវការបញ្ជាក់ត្រឹមត្រូវ។

## ២. ជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត

ក.ច.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតតាមនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៣ ខាងក្រោម៖

**ជំហានទី១**

ប្រធាន ក.ច.ប សួរ៖
- តើអ្នកមាន អ.ខ ឬ ឯ.អ ឬទេ?
- តើអ្នកបានចុះឈ្មោះបោះឆ្នោតហើយឬនៅ?

↓

ប្រធាន ក.ច.ប ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត៖
- ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
- អាយុ ១៨ឆ្នាំឡើងគិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនាឆ្នាំ២០០៩)
- លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់។

បើពុំគ្រប់លក្ខខណ្ឌ →
- បដិសេធដោយ ទ.១០០៩ និងណែនាំបន្ថែមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតតាមករណីដូចក្នុងចំណុចទី៣ខាងក្រោម(ទំព័រទី១១ដល់ទី១៨)

បើគ្រប់លក្ខខណ្ឌ →
- ជម្រាបគាត់ឱ្យទៅជួបអនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប

↓

**ជំហានទី២**

អនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន៖
- សួរទីលំនៅតើគាត់ភូមិនៅណា?
- បំពេញ ទ.១០២២
- ប្រគល់ ទ.១០២២ និងឯកសារដទៃទៀតទៅការីកុំព្យូទ័រ។

↓

**ជំហានទី៣**

ការីកុំព្យូទ័រ៖
- ធ្វើតេស្តស្នាមមេដៃ
- បញ្ចូលទិន្នន័យដោយផ្អែកលើ អ.ខ ឬ ឯ.អ និង ទ.១០២២
- ស្កេនយកស្នាមមេដៃ
- ថតរូប និងឯកសារ
- ប្រគល់ឯកសារជូនអ្នកសុំចុះឈ្មោះបោះឆ្នោតវិញ។

## ៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ

ក្នុងការចុះឈ្មោះបោះឆ្នោត ការកែតម្រូវទិន្នន័យ ការប្តូរការិយាល័យបោះឆ្នោត និងការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៅតាមឃុំ សង្កាត់ ក.ច.ប ត្រូវអនុវត្តតាមករណីជាក់ស្តែងនីមួយៗ ដូចខាងក្រោម៖

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់

ក្រោយអនុវត្តជំហានទី១ រួចហើយ ប្រសិនបើពិនិត្យឃើញករណីដូចខាងក្រោម

➢ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ


គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)

☛ **ប្រធាន ក.ច.ប ត្រូវ៖**

- បដិសេធការសុំចុះឈ្មោះបោះឆ្នោតតាមសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយធ្វើការបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ
- **ណែនាំគាត់ដូចខាងក្រោម៖**
  + សូមទៅរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្ដល់ អ.ខ ជូន
  + ស្នើសុំ ឯ.អ ពីអាជ្ញាធរឃុំ សង្កាត់
  + ជម្រាបគាត់ថា នៅពេលអ្នកទទួលបាន អ.ខ ឬ ឯ.អ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

➢ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតថ្មីមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីឃុំ សង្កាត់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងមិនបានយកមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់


គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)

☛ **ប្រធាន ក.ច.ប ត្រូវ៖**

- បដិសេធការសុំចុះឈ្មោះបោះឆ្នោតតាមសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយធ្វើការបញ្ជាក់ពីមូលហេតុនិងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ
- **ណែនាំគាត់ដូចខាងក្រោម៖**
  + សូមអ្នកទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ពីការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ដែលត្រូវសុំចុះឈ្មោះបោះឆ្នោត
  + ប្រសិនបើគាត់ពុំមានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមទេ គាត់ត្រូវទៅស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់

+ ជម្រាបគាត់ថា នៅពេលគាត់យកសៀវភៅស្នាក់នៅច្បាប់ដើមឬសៀវភៅគ្រួសារច្បាប់ដើមបានហើយ ឬបានទទួលលិខិតបញ្ជាក់ទីលំនៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គាត់ត្រូវត្រឡប់មកជួប ក.ច.បវិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះបោះឆ្នោតក្នុងករណីនេះ ត្រូវអនុវត្តនីតិវិធីដូចតទៅ៖

**ការីកុំព្យូទ័រ ត្រូវ៖**

- ចុចលើម៉ឺនុយ "ប្រតិបត្តិការ" ជ្រើសយកពាក្យ "ទម្រង់ចុះឈ្មោះបោះឆ្នោតថ្មី (ទ.១០២២)"
- បំពេញលេខកូដភូមិ និងលេខកូដការិយាល័យ
- ធ្វើតេស្តស្នាមមេដៃ (ផ្តិតស្នាមមេដៃឆ្វេង បន្ទាប់មកផ្តិតស្នាមមេដៃស្តាំ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ ចំពោះជនពិការដៃ ឬអ្នកខូចខ្ទៅដៃ ត្រូវធីកប្រអប់សម្រាប់អ្នកពិការដៃ ឬខូចខ្ទៅដៃ និងផ្តល់សិទ្ធិដោយប្រធាន ក.ច.ប)
- ថត អ.ខ ប្រភេទថ្មី ឬ ឯ.អ របស់អ្នកចុះឈ្មោះ
- ជ្រើសរើសប្រវត្តិចុះឈ្មោះ (មិនទាន់បានចុះឈ្មោះ)
- ជ្រើសរើសឯកសារចុះឈ្មោះ (អ.ខ ប្រភេទថ្មី ឬ ឯ.អ)
- បញ្ចូលទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ និង បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) របស់អ្នកចុះឈ្មោះបោះឆ្នោត
- ថតរូបអ្នកចុះឈ្មោះបោះឆ្នោត
- ផ្តិតយកស្នាមមេដៃអ្នកចុះឈ្មោះបោះឆ្នោតទាំងសងខាងចំនួន៤(បួន)ដង (ជូតសម្អាត មេដៃជាមុនសិនមុននឹងធ្វើការផ្តិតស្នាមមេដៃ)
- ថតឯកសារបញ្ជាក់ទីលំនៅ (សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ)
- ប្រគល់ឯកសារជូនអ្នកចុះឈ្មោះបោះឆ្នោតវិញ (ជម្រាបគាត់ឱ្យពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់លើឧបទស្សន៍កុំព្យូទ័រទី២)
- រក្សាទុកទិន្នន័យ ។

**ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួច**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់ចុះឈ្មោះបោះឆ្នោតម្តងរួចហើយ ប្រធាន ក.ច.ប ត្រូវបន្តសំណួរថា តើអ្នកធ្លាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ណា? ឆ្នាំណា?

❖ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់រួចហើយឆ្នាំ២០២៦ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យកត់ត្រាមិនត្រឹមត្រូវ**

ប្រធាន ក.ច.ប ត្រូវជម្រាបអ្នកសុំកែតម្រូវឱ្យទៅជួបការីកុំព្យូទ័រ ដើម្បីបន្ត នីតិវិធីស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតរបស់គាត់ ដូចខាងក្រោម៖

- **ករណីទិន្នន័យក្នុងកុំព្យូទ័រត្រឹមត្រូវ តែខុសទិន្នន័យក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)**
  - ការីកុំព្យូទ័រទាញយកទិន្នន័យ តាមរយៈស្នាមមេដៃ អត្តលេខ ឬលេខ អ.ខ ឬនាមត្រកូល នាមខ្លួនរបស់អ្នកស្នើសុំ
  - ចាត់អនុប្រធាន ក.ច.ប ឱ្យធ្វើការកែតម្រូវទិន្នន័យជូនអ្នកស្នើសុំនៅលើ ទ.១០២២ ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុង ទ.១០២២ ដែលខុសទាំងពីរផ្នែកនោះ រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបញ្ជាក់ថា បានកែតម្រូវឈ្មោះ ឬ/និងទិន្នន័យតាមការស្នើសុំ។

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំពុំទាន់ត្រូវបានបញ្ជូនមក គ.ជ.ប**

- **ករណីទិន្នន័យក្នុង ទ.១០២២ ត្រឹមត្រូវ ប៉ុន្តែខុសទិន្នន័យក្នុងកុំព្យូទ័រ**
  - ប្រសិនបើទិន្នន័យមិនទាន់បានបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប ត្រូវចាត់ការីកុំព្យូទ័រឱ្យ៖
    - ចុចលើម៉ឺនុយ "ប្រតិបត្តិការ" បន្ទាប់មកជ្រើសយកពាក្យ "ទម្រង់កែតម្រូវទិន្នន័យសម្រាប់អ្នកចុះឈ្មោះថ្មីឆ្នាំ២០២៦"
    - ទាញយកទិន្នន័យរបស់អ្នកស្នើសុំ តាមរយៈស្នាមមេដៃ អត្តលេខ ឬលេខ អ.ខ ឬនាមត្រកូល នាមខ្លួន
    - ចុចប៊ូតុង "កែតម្រូវទិន្នន័យ" កម្មវិធីនឹងបង្ហាញផ្ទាំងទិន្នន័យរបស់អ្នកស្នើសុំ
    - ធ្វើការកែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) របស់អ្នកស្នើសុំ
    - បន្ទាប់ពីកែតម្រូវទិន្នន័យរួច (ការីកុំព្យូទ័រត្រូវផ្ទៀងផ្ទាត់ទិន្នន័យអ្នកស្នើសុំ) ចុចលើពាក្យ "យល់ព្រម"
    - ផ្តិតស្នាមមេដៃសាមីខ្លួនបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីបញ្ជាក់ថា បានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មកធ្វើការរក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងកម្មវិធីកុំព្យូទ័រ
    - ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។

- **ករណីទិន្នន័យក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ក៏ខុស ហើយទិន្នន័យក្នុងកុំព្យូទ័រក៏ខុស**

ប្រសិនបើទិន្នន័យមិនទាន់បានបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប ត្រូវចាត់ ៖

- ការីកុំព្យូទ័រទាញយកទិន្នន័យ តាមរយៈស្នាមមេដៃ អត្តលេខ ឬលេខ អ.ខ ឬ នាមត្រកូល នាមខ្លួនរបស់អ្នកស្នើសុំ
- អនុប្រធាន ក.ច.ប ត្រូវ៖
  - ធ្វើការកែតម្រូវទិន្នន័យជូនអ្នកសុំនៅលើបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ ) ដែលខុសទាំងពីរផ្នែកនោះ
  - រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបញ្ជាក់ថាបានកែតម្រូវឈ្មោះ ឬ/និងទិន្នន័យតាមការស្នើសុំ។
- **ការកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ ត្រូវ៖**
  - ចុចលើម៉ឺនុយ "ប្រតិបត្តិការ" បន្ទាប់មកជ្រើសយកពាក្យ "ទម្រង់កែតម្រូវទិន្នន័យសម្រាប់អ្នកចុះឈ្មោះថ្មីឆ្នាំ២០២៦"
  - ទាញយកទិន្នន័យរបស់អ្នកស្នើសុំ តាមរយៈស្នាមមេដៃ អត្តលេខ លេខ អ.ខ ឬ នាមត្រកូល នាមខ្លួន
  - ចុចប៊ូតុង "កែតម្រូវទិន្នន័យ" កម្មវិធីនឹងបង្ហាញផ្ទាំងទិន្នន័យរបស់អ្នកស្នើសុំ
  - ធ្វើការកែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) របស់អ្នកស្នើសុំ
  - បន្ទាប់ពីកែតម្រូវទិន្នន័យរួច (ការីកុំព្យូទ័រត្រូវផ្ទៀងផ្ទាត់ទិន្នន័យអ្នកស្នើសុំ) ចុចលើពាក្យ "យល់ព្រម"
  - ផ្តិតស្នាមមេដៃសាមីខ្លួនបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រដើម្បីបញ្ជាក់ថា បានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មកធ្វើការរក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងកម្មវិធីកុំព្យូទ័រ
  - ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។

**ចំណាំ៖**

**ការកែតម្រូវក្នុងករណីនេះ អាចធ្វើបានលុះត្រាតែទិន្នន័យពុំទាន់បានបញ្ជូនទៅ ន.គ.ទ.ប ។**

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំ ត្រូវបាន ក.ច.ប បញ្ជូនមក គ.ជ.ប**

ករណី នេះអ្នកស្នើសុំកែតម្រូវអាចសុំផ្ទៀងផ្ទាត់ទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រជាមួយបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ឬ អ.ខ ឬ ឯ.អ បាន ប៉ុន្តែមិនអាចកែតម្រូវទិន្នន័យបានទេ។ បើទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រមិនត្រឹមត្រូវ ក.ច.ប ត្រូវណែនាំគាត់ឱ្យរង់ចាំប្ដឹងតវ៉ាសុំកែតម្រូវទិន្នន័យនៅក្នុងអំឡុងពេលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

**គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយនាឆ្នាំកន្លងទៅ នៅឃុំ សង្កាត់ផ្សេង**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនាឆ្នាំកន្លងទៅ ក្នុងឃុំ សង្កាត់ផ្សេង ប្រធាន ក.ច.ប ត្រូវបន្តនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖

- ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
  - មានអាយុ១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
  - មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
  - ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ហើយអនុប្រធានត្រូវបញ្ជូន អ.ខ ឬ ឯ.អ ឱ្យការីកុំព្យូទ័រស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតមុននឹងបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត។
- **ករណីរកពុំឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

  អនុប្រធាន ក.ច.ប និងការីកុំព្យូទ័រ ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ដូចករណីធម្មតា ដែលមានបញ្ជាក់ក្នុងជំហានទី២ និងជំហានទី៣ ខាងលើ។
- **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥**

  អនុប្រធាន ក.ច.ប ត្រូវសួរបញ្ជាក់ទីលំនៅ ឬទីសំណាក់ក្នុងភូមិ ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោត និងត្រូវបំពេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) គ្មានអត្តលេខសម្រាប់អ្នកផ្លាស់ប្តូរទីលំនៅដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា ឈ្មោះ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះនោះឱ្យទៅជួបការីកុំព្យូទ័រ។
- **ការីកុំព្យូទ័រ ត្រូវអនុវត្តដូចខាងក្រោម៖**
  - ចុចលើម៉ឺនុយ "ប្រតិបត្តិការ" បន្ទាប់មកជ្រើសយកពាក្យ "ទម្រង់ផ្ទេរចូលក្រៅឃុំ សង្កាត់ (ទ.១០២២គ្មានអត្តលេខ)"

- ស្វែងរកទិន្នន័យអ្នកសុំផ្ទេរការិយាល័យ (ការស្វែងរកតាមរយៈ អត្តលេខ ឬលេខ អ.ខ ឬលេខ ឯ.អ និងការស្វែងរកតាមរយៈនាមត្រកូល និងនាមខ្លួន)
- ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យរបស់អ្នកសុំផ្ទេរ រួចចុចប៊ូតុង "ផ្ទេរចូល"
- ផ្តិតស្នាមមេដៃសាមីខ្លួនទាំងសងខាងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ
- ជ្រើសរើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត (បន្ទាប់ពីជ្រើសរើសទីតាំងការិយាល័យដែលត្រូវផ្ទេរចូល ប្រព័ន្ធនិងបង្ហាញផ្ទាំងជម្រើសមួយឱ្យជ្រើសរើស "កែតម្រូវទិន្នន័យ" ឬ "មិនកែតម្រូវទិន្នន័យ" ប្រសិនបើមិនចង់កែតម្រូវទិន្នន័យចាស់គឺមិនចាំបាច់ធីក "✓" "កែតម្រូវទិន្នន័យ" ទេ គ្រាន់តែចុចលើប៊ូតុង "យល់ព្រម" ទិន្នន័យសុំផ្ទេរនឹងចូលដោយស្វ័យប្រវត្តិ)
- ថត អ.ខ ឬ ឯ.អ ដែលយកមកស្នើសុំផ្ទេរចូល
- ថតរូបចំពីមុខ
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើស្កេននស្នាមម្រាមដៃ ដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងឆ្វេងចំនួន៤ដង និងស្តាំចំនួន៤ដង បញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះនិងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ និងរក្សាទុកឯកសារ
- ចុចលើប៊ូតុង "ផ្ទេរចូល" (ចុចប៊ូតុងធីក "✓" បើពិនិត្យឃើញថាត្រឹមត្រូវ បន្ទាប់មកចុចប៊ូតុង "យល់ព្រម"
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) និង អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**យ.ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោត ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចមានបញ្ជាក់ក្នុងជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត ដោយឱ្យអនុប្រធាន ក.ច.ប បំពេញឆ្នាំ និងគូសធីក "✓" សម្គាល់ក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) បន្ថែម ដើម្បីបញ្ជាក់ពីករណីនេះ និងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់នឹងគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ថ្មី។

**ង. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ ឆ្នាំ**

ប្រធាន ក.ច.ប ត្រូវសុំពិនិត្យមើល អ.ខ ឬ ឯ.អ និងបង្ហាញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) (ប្រសិនបើមាន)។ ប្រសិនបើឯកសារដែលគាត់បង្ហាញត្រឹមត្រូវហើយ ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីដូចខាងក្រោម៖

❖ **ករណីទី១ អ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់**

- **ចាត់អនុប្រធាន ក.ច.ប ឱ្យ៖**
  - ○ បំពេញទម្រង់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រា រួចបោះត្រាបន្ថែមរវាងគល់ទម្រង់ និងបង្កាន់ដៃ
  - ○ ហែកបង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ប្រគល់ឱ្យការីកុំព្យូទ័រ
  - ○ ដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) ភ្ជាប់ជាមួយគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)
  - ○ ណែនាំអ្នកស្នើសុំនោះ ឱ្យទៅជួបការីកុំព្យូទ័រ។
- **ចាត់ការីកុំព្យូទ័រឱ្យ៖**
  - ○ ចុចលើម៉ឺនុយ "ប្រតិបត្តិការ" បន្ទាប់មកជ្រើសយកពាក្យ "ទម្រង់ផ្លាស់ប្ដូរការិយាល័យក្នុងឃុំ សង្កាត់ (ទ.១០២៨)"
  - ○ ទាញយកទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខ ឬ លេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
  - ○ ចុចលើពាក្យ "ផ្ទេរការិយាល័យ" កម្មវិធីនឹងបង្ហាញផ្ទាំងមួយដើម្បីឱ្យធ្វើការផ្លាស់ប្ដូរការិយាល័យ (ដើម្បីផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំទៅការិយាល័យថ្មីក្នុងភូមិដែលគាត់រស់នៅ ដូចបានកំណត់ក្នុង ទ.១០២៨)
  - ○ ស្នើសុំអ្នកសុំប្ដូរការិយាល័យ ផ្ដល់ស្នាមមេដៃបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីបញ្ជាក់ថា គាត់ពិតជាបានស្នើសុំប្ដូរការិយាល័យបោះឆ្នោត
  - ○ ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួននៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើឱ្យអ្នកស្នើសុំផ្ដល់ស្នាមមេដៃ ដើម្បីបញ្ជាក់ការស្នើសុំប្ដូរការិយាល័យបោះឆ្នោត
  - ○ ប្រគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ឱ្យអ្នកស្នើសុំ។

❖ ករណីទី២ អ្នកសុំចុះឈ្មោះបោះឆ្នោតបានស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្ដូរឯកសារចុះឈ្មោះបោះឆ្នោត

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់បានចុះឈ្មោះរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យរបស់គាត់ដូចជាឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត កត់ត្រាមិនត្រឹមត្រូវ ឬទើបបានទទួល អ.ខ ដែលមានសុពលភាព ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់អនុប្រធាន ក.ច.ប ផ្ទៀងផ្ទាត់ឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោត បើត្រឹមត្រូវហើយ ឱ្យបំពេញបង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ ទៅកាន់ការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ការីកុំព្យូទ័រ ឱ្យអនុវត្តដូចខាងក្រោម៖
    - ចុចលើម៉ឺនុយ "ប្រតិបត្តិការ" បន្ទាប់មកជ្រើសយកពាក្យ "ទម្រង់កែតម្រូវទិន្នន័យឆ្នាំ២០២៦ (ទ.១០២៨)"
    - យកស្នាមមេដៃរបស់អ្នកស្នើសុំកែតម្រូវ ដើម្បីទាញយកទិន្នន័យមកធ្វើការកែតម្រូវ ឬស្វែងរកទិន្នន័យអ្នកស្នើសុំកែតម្រូវតាមរយៈលេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
    - ចុចលើពាក្យ "កែតម្រូវទិន្នន័យ" ដើម្បីបញ្ចូលទិន្នន័យអ្នកសុំកែតម្រូវទិន្នន័យ
    - ធ្វើការកែតម្រូវទិន្នន័យ ឬប្ដូរឯកសារ ដោយផ្អែកលើ អ.ខ ឬ ឯ.អ ឬ ឯកសារផ្លូវការដែលត្រឹមត្រូវ
    - ចុចលើពាក្យ "យល់ព្រម"
    - ផ្ដិតស្នាមមេដៃសាមីខ្លួនដែលសុំកែតម្រូវទិន្នន័យ (ករណីអ្នកស្នើសុំជាជនពិការ ឬខូចខ្ទៅដៃ ត្រូវផ្ដល់សិទ្ធិដោយប្រធាន ក.ច.ប)
    - ជម្រាបអ្នកសុំកែតម្រូវ ឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២
    - ប្រគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ឱ្យអ្នកស្នើសុំ។

**ចំណាំ៖**

**ការកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដោយ ន.គ.ទ.ប។**

❖ ករណីទី៣ អ្នកបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ

អ្នកបោះឆ្នោតដែលត្រូវអញ្ជើញមកធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ គឺអ្នកចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប ផ្ដិតមេដៃ) ក្នុងបញ្ជីបោះឆ្នោត ពីមុនមក៖

- ចាត់អនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ការីកុំព្យូទ័រថតរូប និងស្កេនស្នាមម្រាមដៃអ្នកស្នើសុំឡើងវិញ។

**ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានរបាយការណ៍អំពីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាព មានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យឯកសារពាក់ព័ន្ធ
- ចាត់អនុប្រធាន ក.ច.ប ឱ្យបំពេញ ទ.១០២៥ និងរាយការណ៍ជូន កបឃ.ស ដើម្បីអនុវត្ត នីតិវិធីស្រង់ឈ្មោះដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត
- ចាត់ចែងបញ្ជូនបញ្ជីឈ្មោះអ្នកទទួលមរណភាព និងឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់មក ន.គ.ទ.ប យ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីបញ្ចប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមរយៈ លធ.ខប ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។

**៨. ការពិនិត្យ និងសម្រេចរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត**

បន្ទាប់ពីទទួលបានរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ទៅឃុំ សង្កាត់ផ្សេង និងមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដែលបានទទួលពី លធ.ខប ឬ កបឃ.ស ក.ច.ប ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមករណីនីមួយៗ ដោយផ្អែកលើឯកសារសំអាង និងទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រ។ ប្រធាន និងអនុប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាមួយឯកសារសំអាងឱ្យបានច្បាស់លាស់ តាមករណីនីមួយៗ និងទិន្នន័យមួយចំនួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដូចជាលេខ អ.ខ ឬ ឯ.អ នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតជាដើម
- ចាត់ការីកុំព្យូទ័រឱ្យធ្វើការផ្ទៀងផ្ទាត់បញ្ជីនេះជាមួយទិន្នន័យក្នុងកម្មវិធីកុំព្យូទ័របន្ថែមទៀត
- បន្ទាប់មក ប្រធាន និងអនុប្រធាន ក.ច.ប ត្រូវសម្រេចឱ្យការីកុំព្យូទ័រធ្វើការស្នើសុំលុបឈ្មោះអ្នកទាំងនោះ តាមកម្មវិធីកុំព្យូទ័រដែលបានកំណត់មក គ.ជ.ប ដោយភ្ជាប់មកជាមួយនូវឯកសារសំអាង។

## VI. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត



## VII. ការប្រើប្រាស់ទម្រង់បែបបទ

☞ ទ.១០០៩ គឺជាសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលប្រធាន ក.ច.ប ប្រើប្រាស់ក្នុងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ចំពោះអ្នកដែលមិនបានបំពេញតាមលក្ខខណ្ឌកំណត់។ ទ.១០០៩ បំពេញចំនួន ១ច្បាប់ ហើយចុះហត្ថលេខា បោះត្រានៅលើផ្នែកទី១ និងផ្នែកទី២ និងចំកណ្តាលកន្លែងហែកផ្តាច់ បន្ទាប់មកហែកផ្នែកទី២ ប្រគល់ឱ្យអ្នកសុំចុះឈ្មោះ និងផ្នែកទី១ ត្រូវរក្សាទុកដើម្បីដាក់ក្នុងស្បោង «ខ»ទី១ (ទ.១០០៩ មានឆ្នាប់ជូនក្នុងឧបសម្ព័ន្ធ១)។

☞ ទ.១០១១ គឺជារបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ដែល ក.ច.ប ត្រូវបំពេញបន្ទាប់ពីបានបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមឃុំ សង្កាត់។

ប្រសិនបើគ្មានពាក្យបណ្តឹងតវ៉ាដាក់នៅ កបឃ.ស ក្នុងរយៈពេល៣ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ យ៉ាងយូរនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៦។

ប្រសិនបើមានពាក្យបណ្តឹងតវ៉ាដែលបានដាក់នៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ តាមការិយាល័យពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយពាក្យបណ្តឹងចប់ ក.ច.ប ត្រូវធ្វើរបាយការណ៍នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៦ (ទ.១០១១ មានឆ្នាប់ជូនក្នុងឧបសម្ព័ន្ធ២)។

ទ.១០១១ ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១១ ចំនួន ៤ច្បាប់**
- ១ ច្បាប់ ច្រកស្រោមសំបុត្រ សម្រាប់ដាក់ក្នុងកញ្ចប់ «ក»
- ២ ច្បាប់ គិបភ្ជាប់នៅផ្នែកខាងក្រៅកញ្ចប់ «ក»
- ១ ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ដែលបន្ទាប់មករក្សាទុកនៅសាលាឃុំ សង្កាត់។

☞ ទ.១០១២ គឺជារបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែល ក.ច.ប ត្រូវបំពេញ ទ.១០១២ ចំនួន៣ច្បាប់ ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» (ទ.១០១២ មានឆ្នាប់ជូនក្នុងឧបសម្ព័ន្ធ៣)។

ទ.១០១២ ប្រើប្រាស់ ដូចខាងក្រោម៖

**ទ.១០១២ ចំនួន ៣ច្បាប់**
- ២ច្បាប់ ច្រកទៅក្នុងស្រោមសំបុត្រ សម្រាប់ដាក់ក្នុងស្បោង «ខ» (ផ្ញើជូន គ.ជ.ប ចំនួន ១ច្បាប់ និង លធ.ឧប ចំនួន ១ច្បាប់)
- ១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ និងក្រោយមកទុកជាឯកសារនៅសាលាឃុំ សង្កាត់។

☞ **ទ.១០១៣** គឺជាលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារ និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះដែល ក.ច.ប ត្រូវបំពេញ ទ.១០១៣ ចំនួន ៤ច្បាប់ ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់ស្បោង «ខ» (ទ.១០១៣ មានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៨)។

ទ.១០១៣ ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១៣ ចំនួន ៤ច្បាប់**
- ២ច្បាប់ ច្រកស្រោមសំបុត្ររួចដាក់ក្នុងស្បោង «ខ»
- ១ច្បាប់ ដាក់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»
- ១ច្បាប់ ក.ច.ប ទុកសម្រាប់ប្រគល់ ទទួលនៅ លធ.ឧប (ក្រោយមកទុកជាឯកសារឃុំ សង្កាត់)។

☞ **ទ.១០១៤** គឺជាលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ឧប។ លធ.ឧប ត្រូវបំពេញ ទ.១០១៤ ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់ស្បោង «គ» (ទ.១០១៤ មានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៨)។

ទ.១០១៤ ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១៤ ចំនួន ៣ច្បាប់**
- ១ច្បាប់ ច្រកស្រោមសំបុត្ររួចដាក់ក្នុងស្បោង «គ»
- ១ច្បាប់ ដាក់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «គ»
- ១ច្បាប់ ទុកឱ្យមន្ត្រី លធ.ឧប សម្រាប់ប្រើនៅ ពេលប្រគល់ ទទួលនៅ គ.ជ.ប។

☞ **ទ.១០២០** គឺជារបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់។ កបឃ.ស ត្រូវបំពេញ ទ.១០២០ ចំនួន ៣ច្បាប់ ឱ្យរួចរាល់នៅពេលបញ្ចប់ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជូនមក គ.ជ.ប ចំនួន ២ច្បាប់ ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានសម្រេចឱ្យបញ្ចូលឈ្មោះ ឬ/និងទិន្នន័យបន្ថែម ឬ/និងកែតម្រូវឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត ឬ/និងដែលត្រូវបានសម្រេចលុបចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ព្រមទាំងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស ពាក់ព័ន្ធតាមករណីនីមួយៗ (ទ.១០២០ មានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៦)។

ទ.១០២០ ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០២០ ចំនួន ៣ច្បាប់**
- ២ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប
- ១ច្បាប់ រក្សាទុកនៅសាលាឃុំ សង្កាត់។

☞ **ទ.១០២១** គឺជារបាយការណ៍ស្ដីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត។ ក.ច.ប ត្រូវបំពេញ ទ.១០២១ ចំនួន ៤ច្បាប់ ដើម្បី

ធ្វើការផ្ទៀងផ្ទាត់ឱ្យប្រាកដថា ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានទទួលស្មើនឹងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើបូកនឹងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ (ទ.១០២១ មានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៧)។

ទ.១០២១ ប្រើប្រាស់ ដូចខាងក្រោម៖

**ទ.១០២១ ចំនួន ៤ច្បាប់**

- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងកញ្ចប់ដាក់គល់សន្លឹក ទ.១០២២ ដែលបានប្រើហើយ
- ១ច្បាប់ កិបភ្ជាប់ផ្នែកខាងក្រៅនៃកញ្ចប់ដាក់គល់សន្លឹក ទ.១០២២ ដែលបានប្រើហើយ
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្ររួចដាក់ក្នុងកញ្ចប់ដាក់ ទ.១០២២ ដែលនៅសល់មិនទាន់ប្រើ
- ១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ដែលបន្ទាប់មករក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់។

☞ **ទ.១០២២ មានអត្តលេខ** គឺជាទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលអនុប្រធាន ក.ច.ប ប្រើសម្រាប់ចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោតដែលរស់នៅក្នុងឃុំ សង្កាត់ និងបានបំពេញតាមលក្ខខណ្ឌកំណត់។ ទ.១០២២ បំពេញចំនួន ១ច្បាប់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៅលើផ្នែកទី១ និងផ្នែកទី២ និងចំកណ្ដាលកន្លែងហែកផ្ដាច់ បន្ទាប់មកហែកផ្នែកទី២ ប្រគល់ឱ្យការីកុំព្យូទ័រ អនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដែលបន្ទាប់មក ការីកុំព្យូទ័រត្រូវប្រគល់ឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោត និងផ្នែកទី១ (គល់ទម្រង់) ត្រូវរក្សាទុកដើម្បីដាក់ក្នុងកញ្ចប់ដាក់គល់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ (ទ.១០២២ មានអត្តលេខមានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៨)។

☞ **ទ.១០២២ គ្មានអត្តលេខ** គឺជាទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលអនុប្រធាន ក.ច.ប ប្រើសម្រាប់ចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ធ្លាប់បានចុះឈ្មោះនៅឃុំ សង្កាត់ផ្សេង ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី និងបំពេញបានតាមលក្ខខណ្ឌកំណត់។ ទ.១០២២ បំពេញចំនួន ១ច្បាប់ ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៅលើផ្នែកទី១ និងផ្នែកទី២ និងចំកណ្ដាលកន្លែងហែកផ្ដាច់ បន្ទាប់មកហែកផ្នែកទី២ ប្រគល់ឱ្យការីកុំព្យូទ័រអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត បន្ទាប់មកទៀតការីកុំព្យូទ័រត្រូវប្រគល់ឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោត ហើយផ្នែកទី១ (គល់ទម្រង់) ត្រូវរក្សាទុកដើម្បីដាក់ក្នុងកញ្ចប់ដាក់គល់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ (ទ.១០២២ គ្មានអត្តលេខ មានឧទ្ទាប់ជូនក្នុងឧបសម្ព័ន្ធ៨)។

☞ **<u>ទ.១០២៥</u>** គឺជាតារាងចំនួនអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ទ.១០២៥ បំពេញដោយស្មៀនឃុំ សង្កាត់ និង កបឃ.ស (ទ.១០២៥ មានឆ្លាប់ជូនក្នុងឧបសម្ព័ន្ធ៩)។

☞ **<u>ទ.១០២៨</u>** គឺជាបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យព្រមទាំងប្តូរឯកសារចុះឈ្មោះបោះឆ្នោតដូចជា អ.ខ ប្រភេទចាស់ ទៅជា អ.ខ ប្រភេទថ្មី ឬ/និងប្តូរ អ.ខ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រដែលមានរូបភាព និងស្នាមម្រាមដៃ ដែលអនុប្រធាន ក.ច.ប ប្រើប្រាស់សម្រាប់កែតម្រូវទិន្នន័យ ឬប្តូរការិយាល័យបោះឆ្នោតតាមការស្នើសុំរបស់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបានបំពេញតាមលក្ខខណ្ឌកំណត់។ ទ.១០២៨ បំពេញ ចំនួន ១ច្បាប់ ហត្ថលេខាអនុប្រធាន ក.ច.ប និងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត នៅលើផ្នែកគល់ និងផ្នែកចុង និងចំកណ្តាលកន្លែងហែកផ្តាច់ បន្ទាប់មកហែកផ្នែកចុងប្រគល់ឱ្យអ្នកស្នើសុំ និងផ្នែកគល់ត្រូវរក្សាទុកដើម្បីដាក់ក្នុងស្បោង «ខ»។ (ទ.១០២៨ មានឆ្លាប់ជូនក្នុងឧបសម្ព័ន្ធ១០)។

☞ **<u>ទ.១០២៩</u>** គឺជារបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់។ អនុប្រធាន ក.ច.ប ត្រូវបំពេញរបាយការណ៍ ទ.១០២៩ ចំនួន ២ច្បាប់ បន្ទាប់ពីខ្លួនបានធ្វើការផ្ទៀងផ្ទាត់ចំនួនសរុបនៃបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងទិន្នន័យ ទ.១០២៩ ក្នុងកម្មវិធីកុំព្យូទ័រ ជាមួយការីកុំព្យូទ័ររួច ព្រមទាំងធ្វើការបិទផ្សាយរបាយការណ៍នេះ នៅមុខការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ១ច្បាប់ និងរក្សាទុក ១ច្បាប់ជាឯកសារ (ទ.១០២៩ មានឆ្លាប់ជូនក្នុងឧបសម្ព័ន្ធ១១)។

☞ **<u>ទ.១១០៧</u>** គឺជាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារពេលចុះឈ្មោះបោះឆ្នោតដោយ ក្រុមចុះឈ្មោះបោះឆ្នោត ឬ/និងមន្ត្រីប្រគល់ ទទួល ដែលត្រូវបំពេញចំនួន ២ច្បាប់ (ទ.១១០៧ មានឆ្លាប់ជូនក្នុងឧបសម្ព័ន្ធ១២)។

## VIII. ការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប

### ១. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យបោះឆ្នោតនីមួយៗ

ក្រោយពីបានបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត (ទ.១០១១) តាមការិយាល័យបោះឆ្នោតណាមួយរួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់រាល់ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដាក់ចូលក្នុងកញ្ចប់ «ក» និងត្រូវសរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ និងលេខកូដការិយាល័យបោះឆ្នោត សម្គាល់ពីខាងក្រៅកញ្ចប់ «ក» នោះផង។ ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់ «ក» មាន៖

**កញ្ចប់ «ក»**

| | | |
|---|---|---|
| រាជធានី ខេត្ត | ឃុំ សង្កាត់ | ការិយាល័យបោះឆ្នោត |

- *ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គបឃ.ស យល់ព្រមលើពាក្យបណ្តឹងតវ៉ា (ទ.១២០២) ដែលតម្រូវឱ្យ ក.ច.ប ចុះឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន)*
- *ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ១ច្បាប់។*

(កិបភ្ជាប់)
ទ.១០១១ ចំនួន ២ច្បាប់

## ២. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ និងនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់

ក.ច.ប ត្រូវធានាថា រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ និងនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ត្រូវដាក់ទៅក្នុងកញ្ចប់ដោយឡែកពីគ្នាដែលត្រៀមបម្រុងស្រាប់ ដោយដាក់ភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទ (ទ.១០២១) នេះផង។

## ក. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់

**កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះប្រើហើយ**
**(ទ.១០២២ មានអត្តលេខ និងគ្មានអត្តលេខ)**

| | |
|---|---|
| **រាជធានី ខេត្ត** | **ឃុំ សង្កាត់** |

- *រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) គិតទាំងខូចនិងនៅសល់ក្នុងដុំដែលបានប្រើហើយ សរុបក្នុងឃុំ សង្កាត់*
- *ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ១ច្បាប់។*

ទ.១០២១ ចំនួន ១ច្បាប់

## ខ. ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់

ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើ និងរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ដាក់ចូលក្នុងកញ្ចប់ដើម ព្រមទាំងដាក់ក្នុងកេសស័ង្កសី ហើយសរសេរសម្គាល់លេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់ ហើយដែលត្រូវប្រគល់ និងរក្សាទុកនៅ លធ.ខប។ ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់នេះមាន៖

| |
|---|
| **កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ**<br>**ដែលនៅសល់មិនទាន់ប្រើ**<br><br>☐☐ **រាជធានី ខេត្ត** ☐☐☐ **ឃុំ សង្កាត់**<br><br>- *ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ដែលនៅសល់មិនទាន់ប្រើ*<br>- *ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ១ច្បាប់។* |

បញ្ជាក់ ៖

- បន្ទាប់ពីវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ នោះរួច ក.ច.ប ត្រូវដាក់កញ្ចប់នោះទៅក្នុងកេសស័ង្កសី ហើយសរសេរសម្គាល់លេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់ នៅលើកេសស័ង្កសីឱ្យបានត្រឹមត្រូវច្បាស់លាស់។
- កេសស័ង្កសី ដែលដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ ត្រូវប្រគល់ឱ្យ លធ.ខប និងរក្សាទុកនៅ លធ.ខប ស្របពេលនឹងការបញ្ជូន និងការប្រគល់ស្បោង «ខ»។

## ៣. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប

សម្ភារ ឯកសារដែលបានរៀបចំវេចខ្ចប់រួច ក.ច.ប ត្រូវរៀបចំដាក់ក្នុងស្បោង «ខ» បន្តទៀតដើម្បីបញ្ជូនទៅ លធ.ខប។

### ក. ការវេចខ្ចប់ស្បោង «ខ» ទី១

សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «ខ» ទី១ មាន៖




**ពេលចងមាត់ស្បោង «ខ» ទី១ រួច ក.ច.ប ត្រូវ៖**

- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ឱ្យបានត្រឹមត្រូវដោយប៊ិកហ្វឺតលុបមិនជ្រះ
- ដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ១ច្បាប់ ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ» ទី១។

**ចំណាំ៖**

ករណីស្បោង «ខ» ទី១ មានចំនួនសរុបលើសពីមួយ ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្ទៃកខាងក្រៅនៃស្បោង «ខ» ទី១ ទាំងនោះនូវលេខនៃស្បោងនីមួយៗ។ ឧទាហរណ៍ ស្បោង «ខ» ទី១ សរុបមានចំនួន ២ ត្រូវសរសេរសម្គាល់នូវលេខរៀងថា ១/២ ២/២។

